# សេចក្តីថ្លែងការណ៍រួម

## អតីតអភិបាលក្រុងបាវិតបានទទួលទោសដ៏ស្រាល លើករណីបាញ់ស្រ្តីបីនាក់ បង្ហាញពីការផ្ទុយគ្នាយ៉ាងខ្លាំងពីទោសដ៏ធ្ងន់ដែលអ្នកការពារសិទ្ធិមនុស្សបានទទួល

រាជធានីភ្នំពេញ (ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣)៖ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ សូមស្វាគមន៍ការផ្តន្ទាទោសលើលោក ឈូក បណ្ឌិត អតីតអភិបាលក្រុងបាវិត ចំពោះការបាញ់ទៅលើស្រ្តី បីនាក់ ដែលជាកម្មកររោងចក្រកាលពីឆ្នាំមុន ប៉ុន្តែយើងខ្ញុំមិនយល់ស្របទៅលើការចោទប្រកាន់មិនត្រឹមត្រូវ និងការផ្តន្ទាទោសដ៏ស្រាល ដែលគួរឲ្យភ្ញាក់ផ្អើល (ផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ឆ្នាំកន្លះ) ចំពោះសកម្មភាពដែលអាចជាអំពើប៉ុនប៉ងមនុស្សឃាត។

ការផ្តន្ទាទោសនេះ គឺហាក់ដូចជាការវាយថ្នមៗទៅលើកដៃ ហើយក៏ជាសញ្ញានៃវប្បធម៌និទណ្ឌភាពដែលរីករាលដាលរបស់កម្ពុជា ទៅលើអ្នកដែលមានទំនាក់ទំនងល្អជាមួយអាជ្ញាធររដ្ឋ។

យោងតាមសាក្សី អតីតអភិបាលក្រុង លោក ឈូក បណ្ឌិត បានប្រើកាំភ្លើងក្នុងអំឡុងពេលបាតុកម្មនៅរោងចក្រកាត់ដេរ កាលពីខែកុម្ភៈ ឆ្នាំ២០១២ ហើយបានបាញ់ទៅលើក្រុមកម្មកររាប់ពាន់នាក់។ ស្រ្តីចំនួនបីនាក់ បានរងរបួសធ្ងន់ធ្ងរ។ នៅគ្រាមុន លោក បណ្ឌិត មិនទាន់ត្រូវបានឃាត់ខ្លួនសូម្បីតែមួយថ្ងៃ ហើយគាត់ត្រូវបានតុលាការលើកលែងការចោទប្រកាន់ថែមទៀតផង។ ចុងក្រោយគាត់ត្រូវបានចោទប្រកាន់ពីបទ "បង្ករបួសស្នាមដោយអចេតនា"។

ផ្ទុយទៅវិញ សកម្មជនដីធ្លីនៅតំបន់បឹងកក់ និងជាអ្នកការពារសិទ្ធិមនុស្ស អ្នកស្រី យ៉ោម បុប្ផា ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេល ៣ ឆ្នាំ (ទោះបីជាមានការព្យួរទោសរយៈពេល ១ ឆ្នាំដោយសាលាឧទ្ធរណ៍ក៏ដោយ) ទៅលើបទល្មើស "អ្នកផ្តើមគំនិត" លើអំពើហិង្សាដោយចេតនាទៅលើបុរសម្នាក់។ មិនមានភស្តុតាងណាមួយ ត្រូវបានបង្ហាញនៅក្នុងសវនាការ ស្តីពីការពាក់ព័ន្ធរបស់អ្នកស្រីទៅលើការប្រើអំពើហិង្សានោះទេ។ អ្នកស្រី បុប្ផា ត្រូវបានជាប់ក្នុងពន្ធនាគារតាំងពីខែកញ្ញា ឆ្នាំ២០១២ ដែលរួមទាំងការឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការរយៈពេល ៤ ខែ។

អ្នកនាង ណាលី ពីឡូក នាយិកាអង្គការសិទ្ធិមនុស្ស លីកាដូ បានមានប្រសាសន៍ថា៖ "លោក បណ្ឌិត បានបាញ់ទៅលើក្រុមមនុស្សរាប់ពាន់នាក់ ដោយមានសាក្សីជាច្រើនបានឃើញ ហើយបានទទួលទោសជាប់ពន្ធនាគារត្រឹមតែរយៈពេល ៦ ខែ សម្រាប់ជនរងគ្រោះម្នាក់ៗ ដែលគាត់បាន បាញ់។ អ្នកនាងបានបន្តទៀតថា៖ "អ្នកស្រី បុប្ផា មិនមានវត្តមាននៅកន្លែងកើតហេតុ នៅពេលដែលការវាយតប់បានកើតឡើង ហើយក៏មិនមានភស្តុតាងបង្ហាញពីការពាក់ព័ន្ធរបស់អ្នកស្រីទៅនឹងសកម្មភាពនោះទេ ប៉ុន្តែអ្នកស្រី បែរជាត្រូវជាប់ពន្ធនាគាររយៈពេល ២ឆ្នាំទៅវិញ"។

"អ្នកមិនអាច ហៅប្រព័ន្ធតុលាការនេះថាជាប្រព័ន្ធដែលមានបទដ្ឋានពីរផ្សេងគ្នានោះទេ (ប្រព័ន្ធដែលមានភាពខុសគ្នាទាំងស្រុង ចំនួនពីរៈ មួយជាប្រព័ន្ធដែលត្រូវបានគេរក្សាជាមធ្យោបាយសម្រាប់ប្រឆាំងនឹងសកម្មជន ហើយមួយទៀត ជាមធ្យោបាយបម្រើ និងការពារបុគ្គលនានាដែលមានទំនាក់ទំនងល្អជាមួយអាជ្ញាធររដ្ឋ)"។

ករណីលោក បណ្ឌិត គឺជាការនឹកឃើញដល់នីតិវិធីច្បាប់ ដែលត្រូវបានធ្វើកាលពីខែមេសា ឆ្នាំ២០១២ លើករណីឃាតកម្មសកម្មជនបរិស្ថាន លោក ឈុត វុទ្ធី។ បន្ទាប់ពីបង្ហាញនូវការពន្យល់ដែលមិនមានភាពស៊ីចង្វាក់គ្នាជាច្រើនដង ទៅលើការស្លាប់របស់លោក វុទ្ធី អាជ្ញាធរបានអះអាងថាអ្នកសម្លាប់លោក វុទ្ធី ក៏បានស្លាប់ដែរ (ត្រូវបានសម្លាប់ដោយសន្តិសុខនៅនឹងកន្លែងកើតហេតុ)។ បុគ្គលិកសន្តិសុខ រូបនោះ ដែលមានឈ្មោះ រ៉ាន់ បូរ័ត្ន ត្រូវបានផ្តន្ទាទោស ហើយត្រូវបានដោះលែងវិញ បន្ទាប់ពីបានជាប់ពន្ធនាគាររយៈពេល ៦ ខែ។

អ្នកនាង ណាលី ពីឡូក បានមានប្រសាសន៍បន្ថែមថាៈ "ដូចជានៅក្នុងករណីឃាតកម្មលើអ្នកដឹកនាំការពារបរិស្ថាន លោក វុទ្ធី រូបរាងខាងក្រៅ គឺមានភាពមិនល្អ ដែលអាជ្ញាធរនានា ត្រូវបានដាក់ឲ្យឈរនៅជ្រុងម្ខាង"។ អ្នកនាងបានបន្តទៀតថាៈ "អ្នកទាំងនោះ គួរតែធ្វើអ្វីមួយ។ ជាអកុសល ដូចនៅក្នុងករណីលោក វុទ្ធី អ្នកទាំងនោះធ្វើសកម្មភាពតិចតួចបំផុតតាមដែលអាចធ្វើទៅបាន ហើយសកម្មភាពនោះស្ទើរតែមិនបានប្រយុទ្ធប្រឆាំងនឹងវប្បធម៌និទណ្ឌភាពរបស់ប្រទេសទាល់តែសោះ"។

លោក បណ្ឌិត ត្រូវបានបង្គាប់ឲ្យផ្តល់សំណងចំនួន ៣៨ លាន រៀល (៩,៥០០ ដុល្លារ) ដល់ជនរងគ្រោះទាំងបីនាក់ (ជនរងគ្រោះទី១ ទទួលសំណងចំនួន ២០ លានរៀល ស្មើនឹង ៥,០០០ ដុល្លារ ជនរងគ្រោះទី២ ទទួលសំណង១០ លានរៀល ស្មើនឹង ២,៥០០ ដុល្លារ និងជនរងគ្រោះទី៣ ទទួលសំណង ៨ លានរៀល ស្មើនឹង២,០០០ ដុល្លារ)។

ទីក្រុង បាវិត ស្ថិតនៅខេត្តស្វាយរៀង។ តំបន់សេដ្ឋកិច្ចពិសេស គឺជាទីតាំងនៃរោងចក្រវាយនភ័ណ្ឌជាច្រើន ដែលផ្គត់ផ្គង់ដល់ក្រុមហ៊ុនសំលៀកបំពាក់អន្តរជាតិនានាដូចជា Puma ដែលជាអ្នកទិញពីរោងចក្រ ដែលកម្មកររងបួសធ្វើការ នៅពេលមានការបាញ់ប្រហារ។

សាលក្រម បានចេញត្រឹមតែរយៈពេល ៦ ខែ បន្ទាប់ពីមានការចោទប្រកាន់សារឡើងវិញ តាមរយៈសាលក្រមមួយអំពីបទល្មើសឃាតកម្ម ទៅលើលោក ប៊ន សំណាង និងលោក សុខ សំអឿន ដែលត្រូវបានគេចោទប្រកាន់មិនត្រឹមត្រូវ នៅក្នុងការសម្លាប់មេដឹកនាំសហជីព លោក ជា វិជ្ជា កាលពីឆ្នាំ២០០៤។ គ្មានភស្តុតាងណាមួយដែលអាចបង្ហាញថាអ្នកទាំងពីរមានជាប់ពាក់ព័ន្ធ និងបទឧក្រិដ្ឋនោះទេ ហើយតុលាកាកំពូលក៏បានបញ្ជាឱ្យដោះលែងអ្នកទាំងពីរនៅឆ្នាំ២០០៨។ អ្វីដែលចំលែកនោះគឺ សាលក្រមឃុំខ្លួនចំនួន២០ឆ្នាំ របស់ពួកគេត្រូវបានអនុវត្តន៍ឡើងវិញនៅខែធ្នូ ឆ្នាំ២០១២ បើទោះជាគ្មានភស្តុតាងថ្មីត្រូវបានដាក់ជូនទៅតុលាកាក៏ដោយ។

លោក មឿន តុលា ប្រធានកម្មវិធីសិទ្ធិការងារ នៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ បានមានប្រសាសន៍ថា៖ "សាលក្រមទាំងនោះមិនបានជួយអ្វី ដល់កិត្តិយសរបស់ប្រទេសកម្ពុជាក្នុងវិស័យកាត់ដេរដែលជាវិស័យដ៏សំខាន់មួយលើឆាកអន្តរជាតិនោះទេ"។ លោក បានបន្តទៀតថា៖ "សារមួយគឺ៖ ឃាតករសប្បនិម្មិត និងសកម្មជន បានទទួលទោសពន្ធនាគារធ្ងន់ធ្ងរ ទោះបីជាអ្នកទាំងនោះមិនបានប្រព្រឹត្តបទល្មើសណាមួយក៏ដោយ នៅពេលដែលបុគ្គលដែលមានទំនាក់ទំនងល្អជាមួយអាជ្ញាធររដ្ឋ ត្រឹមតែទទួលទោសពន្ធនាគារយ៉ាងស្រាល (ទោះបីជាបទល្មើសរបស់អ្នកទាំងនោះជាបទល្មើសអ្វីក៏ដោយ)។

យើងខ្ញុំ សូមសំណូមពរដល់ព្រះរាជអាជ្ញាខេត្តស្វាយរៀង និងអគ្គព្រះរាជអាជ្ញា សូមមេត្តាប្ដឹងឧទ្ធរណ៍ជំទាស់នឹងសាលក្រមសាលាដំបូងខេត្តស្វាយរៀង ក្នុងការបើកផ្លូវសម្រាប់សាលាឧទ្ធរណ៍ដើម្បីវាយតម្លៃឡើងវិញលើករណីលោក បណ្ឌិត ហើយអនុវត្តការចោទប្រកាន់ និងផ្តន្ទាទោសឲ្យបានត្រឹមត្រូវ និងយុត្តិធម៌ ទៅតាមច្បាប់។ មិនមានករណីណាមួយដែលឲ្យសាលាឧទ្ធរណ៍អនុញ្ញាតឲ្យលោក បណ្ឌិត មានសេរីភាពនោះទេ នៅខណៈពេលដែលបណ្ដឹងឧទ្ធរណ៍របស់លោកកំពុងចំណាត់ការ។

យើងខ្ញុំ ក៏សូមអំពាវនាវដល់អាជ្ញាធរនានា សូមលោកមេត្តាធ្វើការចាប់ខ្លួនលោក បណ្ឌិត ឲ្យបានឆាប់ ដូចនេះ គាត់មិនត្រូវបានអនុញ្ញាតឲ្យរត់គេចខ្លួន ហើយគាត់អាចផ្តល់សំណងទៅដល់ជនរងគ្រោះទាំងបីនាក់នោះ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**


- លោក មឿន តុលា ប្រធានកម្មវិធីសិទ្ធិការងារនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ទូរស័ព្ទលេខ៖ ០៦៦ ៧៧៧ ០៥៦
- លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ ទូរស័ព្ទលេខ៖ ០១២ ៣២៧ ៧៧០